ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ :..........០២៧៤/២៣..............ក.ប/ស.ជ.ណ.ខ.ល

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរៀបចំវាយគង ទូងស្គរ ទះប៉ោត និងគោះត្រដោក នៅតាមរោងចក្រ សហគ្រាស

យោងតាមសារជូនចំពោះជនរួមជាតិកម្ពុជារបស់រាជរដ្ឋាភិបាលលេខ២៥ ស.ល.ខ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៣ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់ម្ចាស់ ឬនាយករោងចក្រ សហគ្រាសទាំងអស់ជ្រាបថា ដើម្បីចូលរួមអបអរព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រដែលគណៈកម្មាធិការបេតិកភណ្ឌពិភពលោក នៃអង្គការយូណេស្កូ បានសម្រេចជាឯកច្ឆ័ន្ទចុះ "**រមណីយដ្ឋានប្រាសាទកោះកេរ**" ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក នាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៣ ក្រសួងសូមណែនាំដល់ម្ចាស់ ឬនាយករោងចក្រ សហគ្រាសទាំងអស់ ត្រូវជួបជុំគ្នាជាមួយបងប្អូនកម្មករនិយោជិតនៅក្នុងបរិវេណសមស្របនៃទីតាំងរោងចក្រ សហគ្រាសរៀងខ្លួន ដើម្បីធ្វើការវាយគង ទូងស្គរ ទះប៉ោត និងគោះត្រដោក តាមគ្រប់មធ្យោបាយដែលខ្លួនមាន **នៅថ្ងៃពុធ ទី២០ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង ៧:០០នាទីព្រឹក** ចំនួន ១៥នាទី ឱ្យបានព្រមៗគ្នា កុំបីអាក់ខានឡើយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ម្ចាស់ ឬនាយករោងចក្រ សហគ្រាស និងកម្មករនិយោជិតទាំងអស់ ត្រូវចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះប្រកបដោយទឹកចិត្តមោទនៈ និងសប្បាយរីករាយចំពោះព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ។

ថ្ងៃចន្ទ ៤កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣
**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល:**
- រដ្ឋបាល រាជធានី ខេត្ត
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត
- សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និង ផលិតផលធ្វើដំណើរនៅកម្ពុជា
- សមាគមស្បែកជើងកម្ពុជា
- សមាគមកាបូប ស្បែកជើង និងអេឡិចត្រូនិច កម្ពុជា
- ឯកសារ កាលប្បវត្តិ